## បញ្ជីសំគាល់

# វត្ថុបុរាណនៃប្រទេសកម្ពុជា ដែលអាចប្រឈមមុខនឹង មហាន្តរាយ



INTERNATIONAL COUNCIL OF MUSEUMS
CONSEIL INTERNATIONAL DES MUSEES
CONSEJO INTERNACIONAL DE MUSEOS
ក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ









Red List
Liste Rouge
បញ្ជីសំគាល់ ICOM

# បញ្ជីសំគាល់

## វត្ថុបុរាណនៃប្រទេសកម្ពុជាដែលអាចប្រឈមមុខនឹង មហន្តរាយ

ជាងពីរសហស្សវត្សមកហើយជនជាតិខ្មែរបានផលិតនូវវត្ថុ ដែលជាទូទៅគេចាត់ទុកថាមានតម្លៃផ្នែកសោភ័ណ។ ភាគច្រើនវត្ថុទាំងនោះជាកម្មសិទ្ធផ្ទាល់នៃស្ថានីយបុរាណរាប់ពាន់កន្លែងដែលមាននៅពាសពេញផ្ទៃប្រទេស។ នាពេលបច្ចុប្បន្នស្ថានីយបុរាណទាំងនោះហើយដែលបង្ហាញឲ្យឃើញនូវប្រវត្តិដ៏ថ្កុំថ្កើងរុងរឿងនៃរាជាណាចក្រកម្ពុជា។ រហូតដល់សព្វថ្ងៃការស្រាវជ្រាវលើប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជានៅមានតិចតួចណាស់ហើយទន្ទឹមនឹងនេះទៀតសោតក៏មានស្គួចស្តើងនៅឡើយដែរ។ ការលួចគាស់កាយស្ថានទីបុរាណនៅប្រទេសកម្ពុជាគ្រប់សម័យកាល ធ្វើឲ្យពិភពលោកទាំងមូលខាតបង់នូវលទ្ធភាពអាចយល់អំពីឫសគល់ដ៏ វិសេសអស្ចារ្យនៃអារ្យធម៌ខ្មែរ។ យោងដូចនេះចាំបាច់ យើងត្រូវបញ្ឈប់ ការជួញដូរវត្ថុបុរាណខុសច្បាប់។

ប្រសិនបើលោកអ្នកយល់ថាមានវត្ថុបុរាណណាមួយចេញពីប្រភពខុសច្បាប់សូមមេត្តាទាក់ទងមកស្ថាប័នខាងក្រោមនេះ ៖

### នគរបាលបេតិកភណ្ឌនៃក្រសួងមហាផ្ទៃ ប្រទេសកម្ពុជា

លេខទូរស័ព្ទ ៖ + ៨៨៥ (០) ១២ ៨២៦ ០១៥
លេខទូរសារ ៖ + ៨៨៥ (០) ២៣ ៧២៦ ៩៧៥
ទំនាក់ទំនង ៖ លោកឧត្តមសេនីយ៍ តាន់ ឆាយ

### ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រទេសកម្ពុជា

លេខទូរស័ព្ទ ៖ + ៨៨៥ (០) ១២ ៨៧២ ៧០៣ / ១៦ ៨២៥ ៨៩៣ / ១៦ ៨៧៣ ៣២៨
លេខទូរសារ ៖ + ៨៨៥ (០) ២៣ ២១៨ ១៤៧
សារអេឡិចត្រូនិច ៖ ok_sophon@yahoo.com
ទំនាក់ទំនង ៖ ឯកឧត្តម ឱក សូផុន

### សារមន្ទីរជាតិកម្ពុជា

លេខទូរស័ព្ទ / លេខទូរសារ ៖
+ ៨៨៥ (០) ២៣ ២១១ ៧៥៣
សារអេឡិចត្រូនិច ៖
museum_cam@camnet.com.kh
ទំនាក់ទំនង ៖ លោក ហាប់ ទូច

## មរតកវប្បធម៌នៃប្រទេសកម្ពុជាស្ថិតនៅក្រោមការគាំពារនៃច្បាប់ និង កិច្ចព្រមព្រាងខាងក្រោមនេះ

### ច្បាប់ជាតិ

រាជក្រឹត្យ ០២៩៥/១២ ស្តីអំពីការបង្កើតអាជ្ញាធរអប្សរ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥

រាជក្រឹត្យ ០១៩៩/១៨ ក្រឹត្យទីពីរ ចំពោះអាជ្ញាធរអប្សរ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩

រាជក្រឹត្យ ០០១/នស ស្តីអំពីការបង្កើតតំបន់វប្បធម៌ការពារ ចុះខែឧសភា ឆ្នាំ១៩៩៤

រាជក្រឹត្យ ០១៩៦/២៦ ស្តីអំពីការការពារមរតកវប្បធម៌ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦

អនុក្រឹត្យលេខ៩៨ ស្តីអំពីការអនុវត្តច្បាប់ការពារបេតិកភណ្ឌវប្បធម៌ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០០២

រាជក្រឹត្យ ០៧០៥/៣២៣ ស្តីអំពីការផ្ទេរតំបន់កោះកេរ ជូនអាជ្ញាធរអប្សរ

រាជក្រឹត្យ ០៥០៤/០៧០ ស្តីអំពីការបង្កើតរមណីដ្ឋានកោះកេរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៤

សាលក្រម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
ស្តីអំពីច្បាប់តុលាការ និងឧក្រិដ្ឋកម្ម និង និតិវិធី ដែលអនុវត្តក្នុងប្រទេសកម្ពុជា
អំឡុងចន្លោះសម័យប្តូររបប
មាត្រាទី៤៧ ស្តីអំពីការទទួល និងលាក់ទុកសម្បត្តិវប្បធម៌

សាលក្រម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
ស្តីអំពីច្បាប់តុលាការ និងឧក្រិដ្ឋកម្ម និង និតិវិធី ដែលអនុវត្តក្នុងប្រទេសកម្ពុជា
អំឡុងចន្លោះសម័យប្តូររបប
មាត្រាទី៤៤ ស្តីអំពីបទល្មើសមជ្ឈមពាក់ព័ន្ធនឹងសម្បត្តិវប្បធម៌

ច្បាប់រដ្ឋបវេណី មាត្រាទី៨ ចុះខែកុម្ភៈ ឆ្នាំ២០០៣

### សិទ្ធិសញ្ញាអន្តរជាតិ

អនុសញ្ញាទីក្រុងឡាអេ ស្តីអំពីការគាំពារសម្បត្តិវប្បធម៌
នៅពេលមានជម្លោះប្រដាប់អាវុធ និងពិធីសាដំបូង
ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤

អនុសញ្ញាយូណេស្កូ ស្តីអំពីមធ្យោបាយនៃបម្រាម និងការបង្ការកុំឲ្យមានការនាំចូល
ការនាំចេញ និងការផ្ទេរសិទ្ធិកាន់កាប់ខុសច្បាប់នៃសម្បត្តិវប្បធម៌

អនុសញ្ញាយូនីដ្រូរ៍ ស្តីអំពីសម្បត្តិវប្បធម៌ដែលត្រូវគេលួច និងនាំចេញខុសច្បាប់
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៥

អនុសញ្ញា ស្តីអំពីការគាំពារសម្បត្តិវប្បធម៌នៅក្នុងទឹក
ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០១

អនុសញ្ញា ស្តីអំពីការគាំពារសម្បត្តិវប្បធម៌អរូបី
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ២០០៣

អនុសញ្ញា ស្តីអំពីការគាំពារ និងផ្សព្វផ្សាយពីភាពទីទៃ នៃវិញ្ញត្តិវប្បធម៌នីមួយៗ
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥

### កិច្ចព្រមព្រាងទ្វេភាគីរវាងប្រទេសថៃ

និងសហរដ្ឋអាមេរិក

២០០៩ ICOM រក្សាសិទ្ធិគ្រប់យ៉ាង

## អារម្ភកថា

បើទោះបីជារដ្ឋាភិបាលនៃប្រទេសកម្ពុជា បានចាត់វិធានការណ៍យ៉ាងតឹងរឹងចំពោះការគាំពារមរតកវប្បធម៌ នៃប្រទេសរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ការលួច និងការបំផ្លាញបុរាណស្ថានគ្រប់ទីកន្លែងនៅតែមានជាបន្តដដែល។ ជាច្រើនទសវត្សរ៍មកហើយ ពួកចោរលួចហានកំណត់មុខព្រួញលួចយកវត្ថុធ្វើអំពីលោហធាតុ និងរូបចម្លាក់ឆ្លាក់អំពីថ្ម ពីសម័យអង្គរ និងក្រោយអង្គរ។ ថ្មីៗនេះការបំផ្លាញទ្រង់ទ្រាយថ្មីមួយទៀតមានលេចឡើងគឺការលួចគាស់កាយទីកន្លែងកប់សប់ពីសម័យបុរេប្រវត្តិមាននៅពាសពេញផ្ទៃប្រទេស។

ការស្វែងរកវត្ថុបុរាណបណ្តាលមកពីមានតម្រូវការនៅក្នុងប្រទេសកម្ពុជា និងនៅលើទីផ្សារអន្តរជាតិ។ ចរាចរវត្ថុ និងសម្ភារៈខុសច្បាប់គ្រប់ប្រភេទធ្វើពីរូបធាតុគ្រប់យ៉ាង ដែលមានអាយុកាលចាប់ពីសម័យបុរេប្រវត្តិរហូតដល់សតវត្សទី១៩ កំពុងធ្វើឲ្យប្រទេសដែលសំបូរទៅដោយមរតកវបវប្បធម៌ឈានឆ្ពោះទៅរកក្តីវិនាសអន្តរាយ។ រូបចម្លាក់ គ្រឿងលម្អនៃស្ថាបត្យកម្ម ឯកសារសាសនាសម័យបុរាណ លង្ហិន វត្ថុសិល្បៈ ធ្វើអំពីលោហធាតុ វត្ថុធ្វើអំពីឈើ និងកុលាលភាជន៍ ត្រូវមានគេនាំចេញដោយខុសច្បាប់ រឹតតែច្រើនឡើង។

ធនធានវប្បធម៌នៃប្រទេសកម្ពុជា គឺមានសារសំខាន់ខ្លាំងបំផុតចំពោះប្រជាជាតិរបស់ខ្លួន។ ដោយសារមោទនភាពនៃមរតកទាំងនេះហើយ បានជាគេដាក់រូបប្រាសាទអង្គរវត្តជាតំណាងនៅលើទង់ជ័យរបស់ប្រទេសកម្ពុជា។ ម្យ៉ាងទៀតឧទ្យានអង្គរក៏មានប្រជាប្រិយភាពសម្រាប់ភ្ញៀវទេសចរអន្តរជាតិដែលអាចជួយលើកស្ទួយវិស័យសេដ្ឋកិច្ចដល់ប្រទេសកម្ពុជាមានមួយកំរិតដែរ។ ដូចនេះ សហគមន៍អន្តរជាតិនៅតែបន្តការយកចិត្តទុកដាក់ទៅលើបញ្ហាទាក់ទងនឹងការបំផ្លាញមរតកខ្មែរជាដរាប។



រូបចម្លាក់នៅប្រាសាទបាគងដែលត្រូវគេលួចដាប់យក
រក្សាសិទ្ធិដោយ Andrew Burke

## គោលដៅ

បញ្ជីនេះរៀបរៀងឡើងក្នុងគោលបំណងដើម្បីជាជំនួយដល់សារមន្ទីរ ដល់អ្នកប្រមូល ដល់សមុច្ច័យ ឈ្មួញវត្ថុសិល្បៈ និងវត្ថុបុរាណ អតិថិជន ព្រមទាំងមន្ត្រីអនុវត្តច្បាប់ ឲ្យស្គាល់ពីសម្បត្តិដែលគេលួច និងនាំចេញខុសច្បាប់ពីប្រទេសកម្ពុជា។ ដើម្បីជួយសម្រួលដល់កិច្ចការខាងលើនេះ បញ្ជីនេះបានបង្ហាញ និងពិពណ៌នាអំពីវត្ថុជាច្រើនប្រភេទដែលអាចប្រឈមនឹងក្តីវិនាសអន្តរាយដោយការជួញដូរខុសច្បាប់នៅលើទីផ្សារវត្ថុបុរាណ។ វត្ថុទាំងនេះស្ថិតនៅក្រោមការគាំពារនៃច្បាប់របស់ប្រទេសកម្ពុជាស្តីអំពីបម្រាមការជួញដូរ និងនាំចេញ។ ដូច្នេះក្រុមព្រឹក្សាអន្តរជាតិនៃសារមន្ទីរ (ICOM) អំពាវនាវដល់ភាគីជួញដូរកុំឲ្យទិញឬលក់វត្ថុណាមួយ ដោយពុំមានត្រួតពិនិត្យឲ្យបានលម្អិតជាមុននូវកម្រងឯកសារស្តីអំពីប្រភព និងទីតាំងដើមនៃវត្ថុនោះ។ យោងទៅតាមភាពសំបូរបែបដ៏មហិមានៃសម្បត្តិទាំងនេះ បញ្ជីសំគាល់វត្ថុបុរាណនៃប្រទេសកម្ពុជាដែលអាចប្រឈមនឹងក្តីវិនាសអន្តរាយមិនមានបង្ហាញវត្ថុឲ្យបានច្រើនបែបនោះឡើយ។ វត្ថុបុរាណទាំងឡាយណាដែលសង្ស័យថាមានប្រភពចេញពីប្រទេសកម្ពុជាត្រូវតែពិនិត្យយ៉ាងម៉ត់ចត់បំផុត និងត្រូវចាត់វិធានការណ៍ប្រុងប្រយ័ត្ន។

សព្វថ្ងៃនៅប្រទេសកម្ពុជា សិប្បកម្មគឺជារបរមួយដែលកំពុងរីកយ៉ាងខ្លាំង។ សិប្បករផលិតវាយនភ័ណ្ឌ វត្ថុខ្មុកម្រក្សណ៍និងចម្លាក់លើថ្ម និងលើឈើដែលអាចប្រដែងនឹងវត្ថុពីសម័យបុរាណបាន។ ការបោះពុម្ពផ្សាយបញ្ជីនេះគ្មានបំណងអ្វីចង់រារាំងដល់ការប្រកបជំនួញប្រភេទនេះ ដែលចាំបាច់បំផុតចំពោះការបន្តនូវប្រពៃណីសិប្បកម្មនៅប្រទេសកម្ពុជានោះឡើយ។

# បញ្ជីសំគាល់វត្ថុបុរាណនៃប្រទេសកម្ពុជាដែល

វត្ថុខាងក្រោមនេះបែងចែកជាក្រុមយើងទៅតាមប្រភេទនៃវត្ថុធាតុដើមដែលគេយកមកធ្វើ។ រូបថតដែលបង្ហាញនូវប្រភេទផ្សេងៗនៃវត្ថុមានទទួលមកពីសារមន្ទីរជាតិកម្ពុជា[1] សាលាបារាំងចុងបូព៌ា[2] និងអង្គការគាំពារមរតក[3] ដែលសរសេរកាត់តាមលំដាប់ដូចតទៅសជក សបចប អគម។ នាពេលបោះពុម្ពឯកសារដែលអស់លោកអ្នកកំពុងអាននេះរូបទាំងប៉ុន្មាននេះ មិនមែនជារូបថតបង្ហាញពីវត្ថុ ដែលគេលួចនោះទេ គឺគ្រាន់តែចង់បង្ហាញពីប្រភេទវត្ថុដែលជាគោលដៅនៃការធ្វើជំនួញខុសច្បាប់ប៉ុណ្ណោះ។ ក្នុងចំណោមប្រភេទទាំងប៉ុន្មាននេះវត្ថុទាំងពួងមានចែកចេញជាបួនសម័យកាល។

## ប្រភេទនៃវត្ថុដែលមានចុះក្នុងបញ្ជីនេះមានដូចតទៅ ៖

### ថ្ម (រួមទាំងថ្មមានតម្លៃ)

#### សម័យបុរេប្រវត្តិ (ពីស.វទី៥ មុនគ.ស ដល់ស.វទី៥ នៃគ.ស)

ក. ឧបករណ៍ប្រើប្រាស់ ដូចជា ដឹង ពូថៅ និងឧបករណ៍ប្រើប្រាស់សម្រាប់ចិញ្ច្រាំរាងដូចពូថៅ ដែលមាន ទំហំចាប់ពី១០ស.ម ទៅ៤០ស.ម។ (រូបទី១)

ខ. អង្កាំ ភាគច្រើនធ្វើអំពីថ្មមានតម្លៃដូចជា អង្កាំពណ៌ក្រហមនិងអង្កាំឆ្នូតពណ៌ត្នោត ហើយប្រភេទខ្លះទៀតអាចមានចម្លាក់ផងដែរ។ (រូបទី២-៣)



1



2



3

1. រូបទី១ ដឹង (ដូចពូថៅ) សម្ភារៈថ្ម ទំហំ ១៥ x ១៨ ស.ម © [3]
2. រូបទី២អង្កាំ ប្រភេទអង្កាំពណ៌ក្រហម និងអង្កាំឆ្នូតពណ៌ត្នោត ទំហំ ៤ស.ម © [3]
3. រូបទី៣ អង្កាំ ប្រភេទអាហ្គេត © [3]

#### សម័យមុនអង្គរ (ពីស.វ.ទី៦ ដល់ស.វទី៨នៃគ.ស)

ក. រូបចម្លាក់ដូចជារូបចម្លាក់ជាខ្សែរឿង ឬក៏បំណែក (ព្រហស្ត ព្រះបាទ ព្រះកេស និងដងខ្លួន) រូបមនុស្ស និងសត្វ (រូបទី៤-៥-៦-៧)









4. រូបទី៤ ព្រះលិង្គ សម្ភារៈ ថ្មភក់ ទំហំ ៨៣ x ២៥ x ២៤ ស.ម © [1]
5. រូបទី៥ ព្រះកេសព្រះពុទ្ធ សម្ភារៈ ថ្មភក់ ទំហំ ២៧ x ១៦ x ១៧ ស.ម © [1]
6. រូបទី៦ ព្រះនរាយណ៍ សម្ភារៈ ថ្មភក់ ទំហំ ១៣៣ x ៤៨ x ២៥ ស.ម © [1]
7. រូបទី៧ ព្រះគណេស សម្ភារៈ ថ្មភក់ ទំហំ ៧៦ x ៤២ x ២០ ស.ម © [1]

ខ. គ្រឿងលម្អ និងបំណែកនៃស្ថាបត្យកម្ម សសរពេជ្រ ផ្តែរ ហោជាង ជើងទម្រនិងចម្លាក់ក្រឡោតទាប (រូបទី៨-៩)

8







គ. សិលាចារឹក ឆ្លាក់នៅលើផ្ទាំងសិលា និងនៅលើមេទ្វារ (រូបទី១០)

8. រូបទី៨ ផ្តែរ សម្ភារៈ ថ្មភក់ ទំហំ ៣៤ x ១០៩ x ២១ ស.ម © [1]
9. រូបទី៩ ផ្តែរ និងសសរពេជ្រ សម្ភារៈ ថ្មភក់ ទំហំ ១៧៦ x ១៦ (អង្កត់ផ្ចិត ១៥ស.ម) © [1]
10. រូបទី១០ ផ្ទាំងសិលាដែលមានឆ្លាក់រូបគោនន្ទិននៅលើឈូក សម្ភារៈ ថ្មភក់ ទំហំ ៩៧ x ៤២ x ៨ ស.ម © [1]

# អាចប្រឈមមុខនឹងមហន្តរាយ

## សម័យអង្គរ (ពីស.វទី៩ ដល់ស.វទី១៣នៃគ.ស)

ក. រូបចម្លាក់ដូចជារូបចម្លាក់ជាខ្សែរឿង ឬក៏បំណែក(ព្រះហស្ថ ព្រះបាទ ព្រះកេស និងដងខ្លួន) រូបមនុស្ស និងសត្វ (រូបទី១១-១២)





11. រូបទី១១ ទេពភេទស្រី សម្ភារៈ ថ្មភក ទំហំ ១២៥ x ២៦ x ២៦ ស.ម ©[1]
12. រូបទី១២ ព្រះឥសូរជាមួយព្រះនាងឧមា និងព្រះនាងគង្គា សម្ភារៈ ថ្មភក់ ទំហំ ១០១ x ៥៣ x ១៣ ស.ម ©[1]

ខ. គ្រឿងលម្អ និងបំណែកនៃស្ថាបត្យកម្ម (រូបទី១៣-១៤-១៥)







13. រូបទី១៣ ផ្តែរ សម្ភារៈ ថ្មភក់ ទំហំ ៦០ x ១៧៣ ស.ម ©[1]
14. រូបទី១៤ បង្កាន់ដៃនាគដែលមានឆ្លាក់រូបគ្រុឌលើនាគ សម្ភារៈ ថ្មភក់ ទំហំ ១៥៨ x ៩៤ x ៥០ ស.ម ©[1]
15. រូបទី១៥ ចម្លាក់ក្រឡោតទាប ដែលមានឆ្លាក់រូបលោកេស្វរព្រះហស្តច្រើន សម្ភារៈ ថ្មភក់ ទំហំ ២៣០ x ១៨០ x ៣១ ស.ម ©[1]

គ.បន្ទះថ្មកិនថ្នាំជាប្រភេទបន្ទះសិលារាងសំប៉ែតនិងផតកណ្តាលហើយគេច្រើនបង្ហាញជាមួយនឹងអង្រែបុកថ្នាំ ធ្វើអំពីថ្ម (រូបទី១៦)



16. រូបទី១៦ បន្ទះថ្មកិនថ្នាំ និងអង្រែកិនថ្នាំ សម្ភារៈ ថ្មភក់ ©[2]

ឃ. សិលាចារឹក (រូបទី១៧)



17. រូបទី១៧ ផ្ទាំងសិលាដែលមានឆ្លាក់ព្រះយម (យមរាជ) លើក្របី សម្ភារៈ ថ្មភក់ ទំហំ ៦០ x ៣៤ x ១៤ ស.ម ©[1]

## សម័យក្រោយអង្គរ (ពីស.វទី១៤ ដល់ស.វទី២០នៃគ.ស)

ក. សីមា ជាបង្គោលថ្មដែលគេដាំសម្រាប់ជាព្រំប្រទល់នៃព្រះវិហារ ហើយមានកំពូលរាងសាជីជួនកាលមានឆ្លាក់រូបបដិមារខាងពុទ្ធសាសនា។



18. រូបទី១៨ សីមា សម្ភារៈ ថ្មភក់ ទំហំ ៥៩ x ៣២ x ៩.៥ ស.ម ©[1]

# បញ្ជីសំគាល់វត្ថុបុរាណនៃប្រទេសកម្ពុជាដែល

## លោហៈធាតុ (លង្ហិន ទង់ដែង ដែក មាស និងប្រាក់)

### សម័យបុរេប្រវត្តិ (ពីស.វទី៥មុនគ.សដល់ស.វទី៥នៃគ.ស)

ក. វត្ថុប្រើប្រាស់ក្នុងពិធីបុណ្យ មានដូចជាស្គរ មានទំហំធំ និងមានគន្លាក់ចង្កេះ ដែលច្រើនតែលម្អ ដោយក្បាច់ផ្កាយនៅផ្នែកកណ្តាល និងលម្អយកកាច់ខ្សែ ភាជន៍ប្រហោងក្នុងរាងដូចជួង មានឆ្លាក់ក្បាច់ផ្សេងៗ និង ជួង។ (រូបទី១៩-២០)

ខ. គ្រឿងអលង្ការ រួមមានកងជើង អង្កាំ ខ្សែក ចិញ្ចៀនរូបក្បាលក្របី ក្រវិល និងកញ្ចក់ ព្រមទាំងវត្ថុធ្វើអំពីលង្ហិន ជាច្រើនទៀតដែលមានក្បាច់អង្កាញ់។ (រូបទី២១)





19. រូបទី១៩ ជួង សម្ភារៈ លង្ហិន ទំហំ ៥៧ x ២៧.៥ x ៣២ ស.ម ©[1]
20. រូបទី២០ ស្គរ សម្ភារៈ លង្ហិន ទំហំ ៥៦.៥ x ៩៥ ស.ម ©[1]
21. រូបទី២១ កងជើង សម្ភារៈ លង្ហិន អង្កត់ផ្ចិត ពី៩ ទៅ១០ស.ម ©[3]
22. រូបទី២២ លោកេស្វរ សម្ភារៈ លង្ហិន ទំហំ ២៤ x ៧ x ៧ ស.ម ©[1]
23. រូបទី២៣ គោ (យានជំនិះរបស់ព្រះឥស្វរ) សម្ភារៈ លង្ហិន ទំហំ ៣៦ x ៦៤ x ៣២ ស.ម ©[1]

### សម័យមុនអង្គរ

ក. រូបតំណាង និងរូបមនុស្ស




ក. វត្ថុប្រើប្រាស់ក្នុងពិធីសាសនា រួមមានវជ្រ (កាំរន្ទះ) កណ្តឹង ខ្យងស័ង្ខ ត្រីបាតភ័ណ្ឌ និងចានដាក់កំទេចធូប រទេះ/គ្រែស្នែងធ្វើអំពីលង្ហិន។ (រូបទី២៤-២៥-២៦-២៧)



24. រូបទី២៤ ទំពក់គ្រែស្នែង (លម្អដោយក្រវិល និងបង្គោល) សម្ភារៈ លង្ហិន ©[1]





25. រូបទី២៥ ជួង(ប្រើប្រាស់ក្នុងពិធីសាសនា) សម្ភារៈ លង្ហិន ទំហំ ១៤ x ៧ ស.ម ©[1]
26. រូបទី២៦ វជ្រ សម្ភារៈ លង្ហិន ទំហំ ១២.៥ x ៤ x ៤ ស.ម ©[1]
27. រូបទី២៧ ខ្យងស័ង្ខមានជើង(ប្រើប្រាស់ក្នុងពិធីសាសនា) សម្ភារៈ លង្ហិន ទំហំ ២៩ x ១១ x ១១ ស.ម ©[1]
28. រូបទី២៨ ក្រវិល សម្ភារៈ លង្ហិន ទំហំ ៤.៧ x ១.៧ ©[1]
29. រូបទី២៩ ក្រឡម្លូស្លា សម្ភារៈ លង្ហិន ទំហំ ៤១ x ៩.៧ ស.ម ©[2]

ខ. គ្រឿងអលង្ការ រួមមានចិញ្ចៀន ក្រវិល ម្កុដ ខ្សែក កងជើង កងដើមដៃ និងកញ្ចក់ធ្វើអំពីលង្ហិនឬក៏មាស។ (រូបទី២៨)។

គ. ប្រដាប់ប្រដារប្រើប្រាស់ក្នុងផ្ទះបាយ រួមមានស្លាបព្រា/វែក ចានគោម និងពន្លាក (រូបទី២៩)

ឃ. រូបចម្លាក់ (រូបទី៣០)





30. រូបទី៣០ ទេពភេទស្រីលុតជង្គង់ (ជើងទម្រកញ្ចក់) សម្ភារៈ លង្ហិន ទំហំ ៣៤ x ២៤ ស.ម ©[1]

### សម័យក្រោយអង្គរ (ពីស.វទី១៤ ដល់ស.វទី២០នៃគ.ស)

ក. ប្រដាប់ប្រដារប្រើប្រាស់ក្នុងផ្ទះបាយរួមមាន ស្លាបព្រា ប៉ាន់ ចានគោម ឆ្នាំងបាយ/ប៉ាន់តែ ធ្វើអំពីលង្ហិន។ (រូបទី៣១-៣២-៣៣)






31. រូបទី៣១ វែក សម្ភារៈ លង្ហិន ទំហំ ៣០ស.ម ©[2]
32. រូបទី៣២ ក្រឡកំបោរ សម្ភារៈ លង្ហិន ទំហំ ១៧ x ១៦ ស.ម ©[2]
33. រូបទី៣៣ ប្រដាប់ប្រដារប្រើប្រាស់ក្នុងផ្ទះបាយ សម្ភារៈ លង្ហិន ©[2]

ខ. អាវុធរួមមាន កាំបិតស្នៀត និងដាវធ្វើអំពីដែក ដែលភាគច្រើនមានដង។ (រូបទី៣៤)



34. រូបទី៣៤ កាំបិតស្នៀត សម្ភារៈ លង្ហិន ទំហំ ២៥ x ៨.៥ x ២ ស.ម ©[2]

គ. វត្ថុប្រើប្រាស់សម្រាប់ពិធីសាសនា រួមមានរូបតំណាង និងរូបមនុស្ស ជួង គ្រឿងប្រដាប់ប្រដារសម្រាប់តម្លើងរទេះ ពពិល ឧបករណ៍ភ្លេងដូចជាគង និងឃ្មោះគ្រប់ប្រភេទ ជើងទៀន ព្រមទាំងក្រឡ ធ្វើអំពីលង្ហិន។ (រូបទី៣៥-៣៦)




35. រូបទី៣៥ ព្រះពុទ្ធរូប សម្ភារៈ ប្រាក់ ទំហំ ៣៦.៧ x ២៨ x ១៤ ស.ម ©[1]
36. រូបទី៣៦ ពពិល(ជើងទៀនប្រើក្នុងពិធីសាសនា) សម្ភារៈ លង្ហិន ទំហំ ២៥ x ១០.៥ x ០.៧ ស.ម ©[1]

# អាចប្រឈមមុខនឹងមហន្តរាយ

## សម្ភារៈធ្វើអំពីសារធាតុសរីរាង្គ

### សម័យក្រោយអង្គរ (ពីស.វទី១៤ ដល់ដើមស.វទី២០នៃគ.ស)

ក. គ្រឿងលម្អស្ថាបត្យកម្ម រួមមានទ្វារ និងចម្លាក់ហោជាងធ្វើអំពីឈើ ។ (រូបទី៣៧)



37. រូបទី៣៧ ចម្លាក់ហោជាង សម្ភារៈ ឈើ © 2

ខ. ព្រះពុទ្ធរូបទ្រង់គ្រឿង ជាទូទៅគេច្រើនលាបម្រក្សណ៍ បិទសន្លឹកមាស និងកែវ។ (រូបទី៣៨)



38. រូបទី៣៨ រូបទេពប្រណមលុតជង្គង់ សម្ភារៈ ឈើលាបម្រក្សណ៍ក្រហម និងបិទសន្លឹកមាស ទំហំ ៩២ x ៤២ x ៥៤ ស.ម © 1

គ. សស្ត្រា ធ្វើអំពីស្លឹកត្នោត ឬក៏ក្រដាស ។ (រូបទី៣៩)



39. រូបទី៣៩ សស្ត្រា សម្ភារៈ ស្លឹកត្នោត ទំហំ ៥៥.៥ x ៥.៥ x ៨.៥ ស.ម © 1

## កុលាលភាជន៍ និងវត្ថុធ្វើអំពីកែវ



### សម័យបុរេប្រវត្តិ (ពីស.វទី៥មុនគ.ស ដល់ស.វទី៥នៃគ.ស)

ក. ភាជន៍ និងក្រឡ មានដូចជាឆ្នាំងដី ចានគោម ចានទាប ចានគោមមានជើង ។ (រូបទី៤០)

ខ. ភាជន៍មានគ្រឿងលម្អ ដូចជាភាជន៍មានគ្រឿងលម្អលើស្មា។ (រូបទី៤១)

គ. អង្កាំកែវ ជាទូទៅមានទំហំតូចប៉ុនគ្រាប់ធញ្ញជាតិ ដែលមានលំដាប់ពីពណ៌ដីឥដ្ឋ ដល់ពណ៌ខៀវ លឿង បៃតង និងពណ៌ក្រហម។ (រូបទី៤២)





40. រូបទី៤០ ឆ្នាំងដី ប្រភេទ ភាជន៍ផុយ ទំហំ ៤៥ x ៣០ ស.ម © 3

41. រូបទី៤១ ភាជន៍មានគ្រឿងលម្អលើស្មា ប្រភេទ ភាជន៍ផុយលម្អដោយដែក ទំហំ ១០ x ១០ ស.ម © 3



42. រូបទី៤២ អង្កាំ សម្ភារៈ កែវ ទំហំ ១០ x ១០ ស.ម © 3

### សម័យអង្គរ (ពីស.វទី៩ ដល់ស.វទី១៣នៃគ.ស)

កុលាលភាជន៍នៅសម័យអង្គរ ភាគច្រើនជាប្រភេទភាជន៍រឹងគ្មានស្រទាប់រលោង ឬក៏មានស្រទាប់រលោងថ្លា ហើយជាទូទៅមានពណ៌ខៀវខ្ចី ពណ៌លឿងឆៅ ពណ៌ត្នោតលាយក្រហមចាស់ ពណ៌ត្នោត ពណ៌បៃតងចាស់ និងពណ៌ខ្មៅ។

ក. ភាជន៍ និងខួចរួមមាន ឆ្នាំង កោដ្ឋិ ផើង ពាងដាក់សព ចានគោមមានគំរប និងខួចមានគំរប ភាជន៍រូបសត្វ និងភាជន៍ខួចទ្រង់ទ្រាយ( សំណល់ភាជន៍មកពីការដុតនៅក្នុងឡ )។



43. រូបទី៤៣ ខួច © 2

ខ. គ្រឿងមានក្បាច់លម្អ (រូបទី៤៤-៤៥)





44-45. រូបទី៤៤-៤៥ គ្រឿង ប្រភេទ កុលាលភាជន៍ ទំហំពី១០ ទៅ៥០ ស.ម © 2

### សម័យក្រោយអង្គរ( ពីស.វទី១៤ ដល់ស.វទី២០នៃគ.ស )

ក. កុលាលភាជន៍ នាវាដែលលិចនៅក្នុងដែនទឹកនៃប្រទេសកម្ពុជា ប្រហែលជាអាចមានកុលាលភាជន៍ ធ្វើជំនួញ មកពីចិន សុខោតី និងវៀតណាម។



46. រូបទី៤៦ ពាង ប្រភេទ ដីឥដ្ឋដុតជាមួយស្រទាប់រលោង ទំហំ ៦១ x ៤៣ ស.ម © 1



ក្រុមព្រឹក្សាអន្តរជាតិនៃសារមន្ទីរគឺជាអង្គការអន្តរជាតិដ៏សំខាន់មួយដែលប្រមូលផ្តុំនូវសារមន្ទីរទាំងឡាយព្រមទាំងអ្នកជំនាញផ្នែកសារមន្ទីទាំងឡាយដែលផ្តាច់ចិត្តចូលធ្វើការអភិរក្ស រក្សាបន្ត និង ផ្សព្វផ្សាយដល់សង្គម នូវតម្លៃនិងសារសំខាន់នៃបេតិកភណ្ឌពិភពលោក ធម្មជាតិ ក៏ដូច វប្បធម៌រូបី ក៏ដូច អរូបី នាពេលបច្ចុប្បន្ន និងទៅអនាគត។

ក្រុមព្រឹក្សាអន្តរជាតិនៃសារមន្ទីរ គឺជាបណ្តាញអន្តរជាតិនៃអ្នកជំនាញខាងផ្នែកសារមន្ទីរដែលមានមុខជំនាញគ្រប់ប្រភេទផ្សេងៗគ្នា ក្នុងនោះមានសមាជិកចំនួន២៦០០០នាក់ដែលកំពុងបម្រើការងារនៅក្នុង១៥១ប្រទេស។

បង្កើតឡើងនៅឆ្នាំ១៩៤៦ ក្រុមព្រឹក្សាអន្តរជាតិនៃសារមន្ទីរ គឺជាអង្គការក្រៅរដ្ឋាភិបាលមិនគិតពីប្រាក់ចំណេញ ដែលមានទំនាក់ទំនងជាផ្លូវការជាមួយអង្គការយូណេស្កូនិងមានឋានៈជាអ្នកព្រឹក្សា ក្នុងក្រុមព្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិ។

ការប្រយុទ្ធប្រឆាំងនឹងការធ្វើជំនួញសម្បត្តិវប្បធម៌ខុសច្បាប់ជាគោលបំណងចម្បងមួយក្នុងចំណោមកម្មវិធីសំខាន់ៗទាំងប៉ុន្មាន របស់ខ្លួនក្រុមព្រឹក្សាអន្តរជាតិនៃសារមន្ទីរ។ បញ្ជីសំគាល់វត្ថុបុរាណនៃប្រទេសកម្ពុជាដែលអាចប្រឈមនឹងក្តីវិនាសមហន្តរាយ ត្រូវបានចងក្រងឡើងដើម្បីទប់ស្កាត់ការបំផ្លាញ ការលួច និងការនាំចេញខុសច្បាប់នូវសម្បត្តិវប្បធម៌ពីប្រទេសកម្ពុជា ហើយនឹងជួយគាំពារមរតវប្បធម៌នៃប្រទេសនេះ។ បញ្ជីនេះ គឺជាសមុច្ច័យបន្ថែមទៅលើបញ្ជីសំគាល់មួយឈុតដែលបានបោះពុម្ពរួចមកហើយសម្រាប់ប្រទេសអាហ្វ្រិក អាមេរិកឡាទីន អ៊ីរ៉ាក់ អាហ្គានីស្ថង់ និងប៉េរ៉ូ។

*http://icom.museum/redlist*

*បញ្ជីនេះបានចងក្រងឡើងក្រោមការជួយឧបត្ថមយ៉ាងធំទូលាយរបស់*

*ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក*
*ការិយាល័យនៃកិច្ចការអប់រំនិងវប្បធម៌*

INTERNATIONAL COUNCIL OF MUSEUMS
CONSEIL INTERNATIONAL DES MUSEES
CONSEJO INTERNACIONAL DE MUSEOS

គ្រឹស្ថាននៃអង្គការយូណេស្កូ
1, rue Miollis 75732 Paris Cedex 15 France
លេខទូរស័ព្ទ +៣៣(០)១ ៤៧ ៣៤ ០៥ ០០
ទូរសារ +៣៣(០)១ ៤៣ ០៦ ៧៨ ៦២
សារអេឡិចត្រូនិច secretariat@icom.museum គេហទំព័រ http://icom.museum

1/09 - TAM TAM TEAM - Cover: Durga, 8th century A.D. 142 x 42 x 16 cm. © NMC.